# បធអប់រំទី

## ស្ដីអំពី: "ពុទ្ធសាសនា និងប្រជាជនខ្មែរ"

ដូចយើងបានដឹងមកហើយថា ប្រជារាស្ត្រខ្មែរ ៩៩% ជាអ្នកកាន់ពុទ្ធសាសនា ។ ការគោរពពុទ្ធសាសនានេះ មាន តាំងពីសម័យបុរាណ គឺតាំងពីមុនសម័យអង្គរទៅទៀត ។



ការគោរពពុទ្ធសាសនាតៗគ្នារាប់សតវត្សរ៍បែបនេះ បានធ្វើ ឲ្យទស្សនវិជ្ជាពុទ្ធសាសនា ជ្រួតជ្រាបជិតជាប់ក្នុងផ្នត់ចិត្ត

គំនិតរបស់ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស ។ ផ្នត់ចិត្តគំនិតនេះ បានក្លាយទៅជា "**ទស្សនៈរួមរបស់ជាតិ**"ដែល មនុស្សខ្មែរសព្វថ្ងៃមានមកពីកំណើត ។ ទោះអ្នកនោះ មិនបានទៅវត្តរៀនធម៌អាថ៌ក៏ដោយ ក៏ទស្សនៈព្រះពុទ្ធដែលបន្តពីឪពុកម្តាយ បានជ្រួតជ្រាបចូលទៅដល់បុត្រធីតារួចស្រេចទៅហើយ ហើយដែលមិនអាចធ្វើឲ្យប្តូរផ្លាស់បានដោយងាយៗឡើយ ។ ជាពិសេស ប្រជាពលរដ្ឋជាកសិកររស់នៅតាមជនបទ រមែងផ្សារភ្ជាប់ខ្លួនគេទៅនឹងវត្តអារាម និងជួយទ្រទ្រង់វត្តឲ្យមានជីវិតជានិច្ចនិរន្តរ៍រហូតមក ។ ទីណាមានប្រជារាស្ត្រខ្មែររស់នៅទីនោះមានវត្ត ។ តាមតួលេខក្នុងឆ្នាំ ១៩១៦ នៅក្នុងទូទាំងប្រទេសមានវត្តអារាមចំនួន ២.៥០៥ វត្ត ដែលក្នុងនោះមាន ២១វត្ត នៅក្នុងរាជធានីភ្នំពេញ ។ ព្រះសង្ឃមានចំនួន ៣០.០០០អង្គ ។ បើប្រៀបទៅនឹងពលរដ្ឋ ប្រហែល២លាននាក់ គឺជាវត្តមួយសម្រាប់ប្រជាជនខ្មែរចំនួន៨០០នាក់ និងក្នុងចំណោមមនុស្ស ៦៦នាក់ មានព្រះសង្ឃ ១អង្គ ។ ដល់មកឆ្នាំ ១៩៦៩ វត្តបានកើនដល់ ៣.៣៦៩ ក្នុងនោះវត្តធម្មយុត្តិកនិកាយមាន១៣៩វត្ត ។

ព្រះសង្ឃមានចំនួន ៦៥.០៦២អង្គ ក្នុងនោះព្រះសង្ឃធម្មយុត្តមាន២.៣៨៤អង្គ ។ បើធៀបនឹងចំនួនប្រជាជនប្រហែល ៧លាននាក់ ឃើញថាវត្តមួយសម្រាប់ប្រជាជន ៩២នាក់ ។ លុះមកដល់អំឡុងឆ្នាំ១៩៩៤ ស្ថិតិនៅទូទាំងប្រទេសមានវត្តចំនួន៣.០៨៧វត្ត ព្រះសង្ឃមាន ២៧.៥៣៩ អង្គ បើធៀបនឹងប្រជាជន ឃើញថាវត្តមួយសម្រាប់ប្រជាជន២.២៦៧នាក់ ។ ព្រះសង្ឃ១អង្គ សម្រាប់ប្រជាជន ២៥៤នាក់ ។ គិតតាមចំនួនប្រជាជន ៧.០០០.០០០ នាក់ ។ ដូច្នេះបានជាគេនិយមពោលថា វត្តជាជីវិតរបស់ខ្មែរ និងតំណាងនៃអាទិភាពរបស់ខ្មែរ ។



ដោយឡែក ក្នុងបច្ចុប្បន្នភាពនេះ សទ្ធាភាវៈ នៃប្រជាពលរដ្ឋ នៅប្រទេសកម្ពុជាយើង ទៅលើព្រះពុទ្ធសាសនា

មានត្រឹមតែ ៩០% ប៉ុណ្ណោះនៃប្រជាជន១៥លាននាក់ ហើយប្រជាជន១៣លាន៥សែននាក់ គោរពប្រណិបតន៍ព្រះពុទ្ធរតន៍ ។ ចំពោះស្ថិតិទីវត្តអារាមទូទាំងផ្ទៃប្រទេសសព្វថ្ងៃនេះ មានចំនួន៤.៥៥៣វត្ត និងស្ថិតិព្រះសង្ឃសរុបទាំងអស់ ៥៤.០០០អង្គ ។ បើតាមស្ថិតិនេះ បរិមាណនៃពុទ្ធសាសនិក ២.៩៦៦នាក់ សមាមាត្រទៅនឹងទីវត្តអារាម ១ និងពុទ្ធសាសនិក ២៥០នាក់ សមាមាត្រទៅនឹងព្រះសង្ឃ ១អង្គ (នេះបើតាមស្ថិតិព.ស.២៥៥៧គ.ស.២០១៣) ។ យោងតាមសន្ទស្សន៍ស្ថិតិនេះ សរបញ្ជាក់ឲ្យឃើញថា បរិមាណភាពនៃអ្នកបួសនៅក្នុងឆ្នាំ១៩៦៩ មានកំណើនលើសស្ថិតិបច្ចុប្បន្ន ១១.០៦២អង្គ, ប៉ុន្តែស្ថិតិព្រះសង្ឃបច្ចុប្បន្នមានកំណើនលើសស្ថិតិព្រះសង្ឃឆ្នាំ១៩៩៤ ចំនួន ២៦.៧៦១អង្គ, ចំណែកឯ ចំនួនវត្តអារាមនៅតែកើនឡើងជាលំដាប់ដដែល ។

តែការកើនឡើងជាគំហុក នៃបរិមាណភាពវត្តអារាមនេះ ពុំមែនជាមោទនភាព ឬវឌ្ឍនភាពចំពោះភារវិស័យនៃ

ស្ថាប័នព្រះពុទ្ធសាសនាប៉ុន្មានទេ ព្រោះដូចយើងបានឃើញ
ហើយថា ក្នុងពេលបច្ចុប្បន្ននេះ មានជនខិលខូចច្រើន
ណាស់ យកព្រះពុទ្ធសាសនាជាមុខរបរជាអាជីព ជាផ្ទាំង
ចិញ្ចឹមក្រពះ ដោយហោចទៅសូម្បីអ្នកបួសពួកខ្លះ ។ អ្នក
បួសខ្លះ ចេញពីសង្គ្រាមចេះដឹងតែច្បាប់ទាហាន លុះបាន
បួសហើយក៏ស្រវាចង់បានធំតែម្តង, អ្នកបួសខ្លះទៀត ជាអ្នក
ប្រមឹកខ្ជួបស្រវឹងអ្នទីន្ទ សល់ពីគ្រួសារឬសល់ពីប្រពន្ធទាត់
ចោល គ្មានទីពឹងដើរតែលតោលក៏ចូលជ្រកកោនក្នុងព្រះ-
ពុទ្ធសាសនា តែមិនបានសិក្សាធម៌វិន័យអ្វីទេ បួសបែបទំនង
ដុះក្បាលពោះធំសម្ពុយបន្តិច ក៏ឯងឡើងចាងកាងចង់បាន
តំណែងជាព្រះគ្រូចៅអធិការជាដើម, ចំណែកអ្នកបួសខ្លះ
ទៀតនោះ ចេញពីបាតសង្គមជាអ្នកញៀនថ្នាំ ប្រព្រឹត្តអំពើ
អនាចារផ្សេងៗ លុះចូលបួសហើយអត់ធន់នឹងពាក្យទូន្មាន
នៃគ្រូអាចារ្យមិនបាន ក៏តាំងបង្កកម្លាំងបាយបង្កើតរឿងរ៉ាវ
ឲ្យវត្តអារាមចលាចលជាដើម ។ ប៉ែកខាងគ្រហស្ថពួកខ្លះ
វិញ ក៏មិនណាយដែរ អ្នកខ្លះសឹកពីបួសហើយបានចំហាយ
ចេះដឹងកាលពីនៅជាសង្ឃ ឬបានតួនាទីជាអាចារ្យគណៈ

កម្មការ ក៏តាំងវាយឫកលើកកម្ពស់ខ្លួនស្មើនឹងព្រះសង្ឃ ត្រួតត្រាលោកក្នុងវត្ត បង្គាប់បញ្ជាព្រះសង្ឃតាមទំនើងចិត្តខ្លួន ដោយគ្មានគិតខ្លាចពីបាបកម្មធ្វើអ្វីកល្យាណសោះឡើយ ។ ថ្ងៃណាពីអ្នកសឹកពីបួសខ្លះទៀត សឹកមិនចំសឹក បួសមិនចំបួស តាជីមិនចំតាជី តាំងខ្លួនជាអ្នកប្រព្រឹត្តដូច **ព្រះវេស្សន្តរ** សំអាងបានកំណាត់សមកព័ទ្ធរុំខ្លួន ក៏បង្អួតឥរិយាបថជា**សីលព្វតបរាមាស**:ឲ្យអ្នកតោតល្ងង់គោរពបូជាស្មើរតែលើសព្រះរតនត្រ័យទៅទៀត ធ្វើឲ្យតម្លៃព្រះសង្ឃធ្លាក់ចុះ ដូចពាក្យសុភាសិតខ្មែរចំណាំតែពោលថា **"មាសថោកជាងសំណ"** ។

អ្វីដែលបានលើកឡើងមកនេះ គឺជា**ភាពអសកម្ម**របស់ពុទ្ធសាសនិក ដែលមិនត្រឹមតែមិនជួយជ្រោមជ្រែងស្ថាប័នព្រះពុទ្ធសាសនាដ៏ផូរផង់ប៉ុណ្ណោះទេ ថែមទាំងជាធ្មឹងទទឹងកនៃព្រះពុទ្ធសាសនាទៅទៀត នាំគ្នាកែនគូកនបក្សពួក រំលាយព្រះពុទ្ធសាសនាឲ្យដុនដាបកាន់តែខ្លាំង ។

ខ្ញុំ **(លីប៊ុនលីន)** បានធ្វើការសង្កេតកន្លងមកមានចំណុចប្រផ្ទួលចំនួន៦ប្រការ ដែលឧបសគ្គ ជាមហាមេ

គ្រោះចង្រៃ និងជាអចលករនៃវិស័យព្រះពុទ្ធសាសន៍ គឺះ

១.**រដ្ឋាភិបាល** គឺរដ្ឋាភិបាលខ្វះវិធានការ ចំពោះជនឱកាសនិយមក្នុងពុទ្ធសាសនា ដូចករណីលោក **ជាន វុទ្ធី**...។

២.**ជួរមន្ត្រីសង្ឃគ្រប់លំដាប់ថ្នាក់** ភាគច្រើននៃជួរមន្ត្រីសង្ឃទាំងនោះ អសមត្ថភាព ស្រេកឃ្លានអំណាចតំណែង លោភលាភសក្ការៈ មិនមែនការគ្រប់គ្រងតាមដានត្រួតពិនិត្យ និងពង្រឹងព្រះសង្ឃក្រោយៗឲ្យចេះដឹងតាមប្រព័ន្ធព្រះពុទ្ធសាសនា និងគោលការណ៍ផ្លូវលោក...។

៣.**ផ្នែកក្រសួងធម្មការនិងសាសនា** ការចុះត្រួតពិនិត្យស្ថានភាពវត្ត ការពង្រីកកម្មវិធីពុទ្ធិកសិក្សា ការពង្រឹងនិងពង្រាយគ្រូឧទ្ទេសាចារ្យ ប្រកបដោយទេពកោសល្យអមដោយប្រាក់បៀវត្សល្មមរស់សមរម្យ នៅមានកម្រិតនៅឡើយ ហើយតិចតួចបំផុត...។

៤.**ចលភាពជំនឿនៃពុទ្ធសាសនិករប៉ាក់របើក** គឺពុទ្ធបរិស័ទមានការជឿជាក់នៅមានកម្រិត ភាគច្រើននៃពួកគាត់ពុំបានសូវសិក្សានូវបុព្វសិទ្ធិរបស់ពុទ្ធសាសនា ជាដុំកំភួនប៉ុន្មានទេ ច្រើនតែចេះចាំតៗតាមចាស់ទុំបរមបុរាណ

មក, ហេតុនេះ ទើបក្រសែជំនឿរបស់ពួកគាត់នៅមានកម្រិត ។

**៥.កង្វះសាមគ្គីភាពនៃអារាមិកសង្ឃ អាចារ្យ និងគណៈកម្មការវត្ត** អង្គភាពទាំងអស់នេះ ពុំមានភាពស្មោះត្រង់ បាក់បែកប្រេះឆា មិនទុកចិត្តគ្នា ការចេះដឹងខាងសាសនា និងសង្គមមិនឆ្លើយតបនឹងស្ថានភាពជាក់ស្តែង, បើការគ្រប់គ្រងដឹកនាំកាច់ចង្កូតវត្តវិញ នៅមានគំនិតចាស់គំរិលធ្វើឲ្យសង្គមខាងក្រៅ ដែលចេះតែវិវឌ្ឍពីមួយថ្ងៃទៅថ្ងៃនោះ គេទិតៀនមើលស្រាលរបៀបរបបព្រះពុទ្ធសាសនា និងវាយតម្លៃព្រះពុទ្ធសាសនាតែផ្តាសតាមទំនើងចិត្ត ។

**៦.បុគ្គលិកលក្ខណៈនៃព្រះសង្ឃជាសាមីអង្គផ្ទាល់** អ្នកបួសអង្គខ្លះ មានភាពខ្ជិលច្រអូសទម្រន់ មិនមានការខ្នះខ្នែងក្នុងត្រៃសិក្ខានិងពហុសិក្ខា បណ្តោតបណ្តោយខ្លួនឲ្យវង្វេងកំណើត ដោយគិតថាខ្លួនបានបួសហើយ ក៏ហាក់ដូចជាអស្ចារ្យ, លុះពេលមានបញ្ហាកើតឡើង ខ្លួនមិនបានយល់ដឹងក៏ដោះស្រាយមិនចេញ ធ្វើឲ្យពួកអ្នកស្រុកមើលងាយមើលស្រាល ។ ម្យ៉ាងទៀត នៅពេលខ្លួនត្រឡប់

លាចាកសិក្ខាបទទៅគ្រហស្ថវិញ ជាអកុសលមិនបានសិក្សារៀនមុខវិជ្ជាអ្វីជាដុំកំភួននុ៎ះ ហើយកាលខ្លួនធ្លាប់នៅជាសង្ឃសោយសុខដោយចង្ហាន់ ដែលទាយកគេយកមកប្រគេនដល់កន្លែង ស្មើរតែលើសព្រះពុទ្ធជាម្ចាស់ ក៏តាំងក្ញេចក្ញាំងស្មារតីកែប្រែឥរិយាមារយាទ ឲ្យដូចគេគ្រហស្ថធម្មតាមិនទាន់ ទើបឆ្ញោយផ្ដើមបញ្ចេញឫកពាអេះអុញតុញតុះ ធ្វើឲ្យគេម៉ៃវាយតម្លៃខ្លួនជាងពីកាលមិនទាន់បួសទៅទៀត មិនតែប៉ុណ្ណោះឡើយ ចំហាយក្លិនអាក្រក់នេះបានជះឥទ្ធិពលទៅលើអ្នកបួសក្រោយៗ ឲ្យជាប់ក្លិនស្អុយជាមួយខ្លួនទៀតផងដែរ ។

ប្រផ្នូល៦ប្រការនេះ ជាអពមង្គលបំផុតនៅក្នុងសង្គមខ្មែរយើង ដែលកំពុងស៊ីរូងយ៉ាងជ្រៅចូលទៅក្នុងព្រះពុទ្ធ-សាសនាដ៏ស្អាតស្អំឲ្យវិនាសអន្តរាយ ៕

(សម្រួលបន្ថែម ដោយឧត្តមសាចារ្យអគ្គសិរីវិមលញ្ញាណ **លី ប៊ុនលីង**)

# អត្ថបទសម្រង់

## របស់លោកគ្រូព្រះមហាជម្នាលវង្គ្លាពោ ចាន់ សុជន

ប្រជានកម្មវិធីនាធីសំឡេងព្រះធម៌វត្តប្រាសាទស្រះកណ្ដាល(ខ្ពស់)

ចានពិនិត្យ

និជឯកកាព

*ធ្វើនៅវត្តប្រាសាទស្រះកណ្ដាល(ខ្ពស់)*
*ថ្ងៃ ៨កើត ខែស្រាពណ៍ ព.ស.២៥៥៨*
*ត្រូវនឹងទី០៣ ខែសីហា ឆ្នាំ២០១៤*